# ទួលអង្ករខ្មៅ

នៅភូមិកាំងតេដោ ឃុំថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់[១] ខេត្តស្ទឹងត្រែង និងនៅឃុំគយមែង ស្រុកមង្គលបុរី មានទីទួលមួយឈ្មោះថា «ទួលអង្ករខ្មៅ»។ ទីទួលអង្ករខ្មៅនេះមិនមានច្រើនកន្លែងទេនៅក្នុងប្រទេសខ្មែរយើង។ ផ្អែកតាមលោក បណ្ឌិត ធុយ ចាន់ធួន ដែលបានយកអង្ករខ្មៅនៅស្រុកថាឡាបរិវ៉ាត់ទៅពិសោធ បានទទួលលទ្ធផលថាអង្ករខ្មែរនោះមានអាយុកាលនៅស.វ.ទី១០នៃគ្រិស្តសករាជ។[២] នៅក្នុងអត្ថបទនេះ យើងនឹងពិនិត្យមើលថាហេតុអ្វីមានអង្ករខ្មៅនេះ?

អង្ករខ្មៅនេះ ពុំមែនជាអង្ករធម្មជាតិដែលមានព័ណ៌ខ្មៅនោះទេ ប៉ុន្តែជាស្រូវដែលដុតឆេះសម្បក នៅសល់តែសាច់អង្ករ ដែលកើតឡើងដោយចំហេះពុំសព្វ។ បើមើលទៅលើរឿងដុតស្រូវនេះ យើងឃើញមានភស្តុតាងក្នុងសិលាចារឹកមួយចំនួនដែលសរសេរថា «តុតិស្រូវ» មានន័យថា «ដុតស្រូវ»។ ពុំមានសិលាចារឹកដែលរៀបរាប់ដោយចំនិងលម្អិតអំពីកិច្ចពិធីដុតស្រូវនោះឡើយ។ នៅក្នុងសិលាចារឹកស្តុកកក់ធំ K.235 មាននិយាយអំពីព្រំប្រទល់ដីមួយកន្លែងដែលលាតសន្ធឹងទៅដល់ «ក្រលាដុតស្រូវ» (ក្រលាតុតិស្រូ) ដែលយើងអាចយល់បានថាជាទីកន្លែងក្រលាដុតស្រូវនោះ ពុំមែនជាទីតាំងមានទំហំតូចជាធម្មតា ឬជាទីតាំងដែលគេធ្វើចល័តនោះឡើយ។ ប្រសិនបើទីតាំងនោះ ជាទីតាំងដែលគេធ្វើចល័ត ម៉្លេះសមគេពុំយកធ្វើជាទីតាំងគោលសម្រាប់កំណត់ព្រំដីនោះឡើយ។ នេះហាក់ដូចជាស៊ីគ្នានឹងទីទួលអង្ករខ្មៅដែលគេជួបប្រទះ គឺមានលក្ខណៈជាទួលធំសមល្មមនិងមានអង្ករខ្មៅនោះច្រើន។ ចំណែកឯនៅក្នុងសិលាចារឹកប្រាសាទលាក់នាង K.265N នៅក្បែរប្រាសាទប្រែរូប ក៏មាននិយាយអំពីដង្វាយដែលគេថ្វាយសម្រាប់វេលាដុតស្រូវ និងកន្លែងដុតស្រូវ (វេលាតុតិស្រូ & នាតុតិស្រូ) ផងដែរ។ ដូច្នេះយើងឃើញថា «ដុតស្រូវ» នេះ

---

[១] ជាស្ថាននាមក្លាយមកពីពាក្យសំស្ក្រឹត ធារាបវ៌ត (ខ្មែរថា ធារាបព៌ត)។

[២]សូមអាន https://bit.ly/3azov1r។ យើងពុំដឹងច្បាស់ថា តើគ្រាប់អង្ករខ្មែរដែលយកទៅពិសោធនោះ យកពីទួលនោះជម្រៅណានោះឡើយ ដ្បិតគ្រាប់អង្ករខ្មៅដែលយកពីស្រទាប់ដីផ្សេងគ្នាទៅពិសោធ នឹងមានអាយុកាលផ្សេងៗគ្នាដែរ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

គឺជាកិច្ចពិធីដែលគេធ្វើក្នុងកាលវេលាសន្មតិណាមួយ។ បើពិនិត្យមើលនៅក្នុងកំណត់ហេតុមន្ត្រីជាតិចិនគឺលោក ជីវ តាក្វាន់ វិញ នៅត្រង់ចំណុចពេលចូលឆ្នាំក៏មានបង្ហាញឱ្យដឹងថានៅក្នុងខែនីមួយៗប្រចាំឆ្នាំ រមែងមានកិច្ចពិធីប្រចាំខែនោះជានិច្ច។ នៅខែទី៧ មានពិធីមួយគឺពិធីដុតភ្នំស្រូវ[៣] ប៉ុន្តែលោកមិនបានរៀបរាប់លម្អិតអំពីពិធីនេះ ប្រព្រឹត្តិទៅដោយរបៀបណា និងដើម្បីអ្វីនោះទេ។

ចំណែកឯក្នុងវចនានុក្រមខ្មែរវិញត្រង់មេពាក្យ **បរមាយ** ពន្យល់ថា «*ឈ្មោះព្រះរាជពិធីមួយយ៉ាងពីក្នុងបុរាណរាជ្យ, ធ្វើក្នុងខែមាឃ, មានពិធីហែស្ដេចមាឃ, បរសេះ, បរគោ, បរក្របី ប្រណាំង ហើយបរក្របីបញ្ចូលរាង, រួចធ្វើភ្នំស្រូវមួយឲ្យពួកបារគូទាំង៤ក្រុម នាំគ្នាដុតភ្នំស្រូវនោះ, ក្នុងវេលាភ្លើងកំពុងតែឆេះ, មន្ត្រីទីស្ដេចត្រាញ់ខែត្រក្រៅ៥នាក់ ការរំលំភ្នំស្រូវនោះ, បើភ្នំស្រូវនោះរលំទៅទិសណា សន្មតថាពួកប្រជាជនក្នុងទិសនោះនឹងធ្វើស្រូវបានផលច្រើន*»។[៤] ត្រង់ចំណុចនេះ បើយើងបកទៅពិនិត្យមើលសៀវភៅព្រះរាជពិធីទ្វាទសមាសវិញ បង្ហាញថាក្នុងខែមាឃមានព្រះរាជពិធីពីរគឺ **ព្រះរាជពិធីពូនភ្នំស្រូវ** និង **ព្រះរាជកុសលមាឃបូជា**។ ប៉ុន្តែព្រះរាជពិធីពូនភ្នំស្រូវនោះ ពុំមានធ្វើទៀតទេ។ នៅក្នុងឯកសាររបស់សម្ដេចឥសីកទ្ធបតី ម៉ាំង ចាងហ្វាងក្រុមបារគូ បញ្ជាក់ថាភ្នំស្រូវក្នុងកិច្ចពិធីនោះត្រូវដុត ហើយចៅហ្វាយស្រុកទាំង៥ យកដង្ការដែកទាំង៥ ការក្អមទឹកលត់ភ្លើង។ យើងឃើញថាកិច្ចពិធីដុតភ្នំស្រូវនេះ ពុំដុតស្រូវឱ្យឆេះអស់នោះទេ គឺត្រូវមានទឹកមកពន្លត់ផងដែរ។[៥] ម្យ៉ាងទៀតកិច្ចពិធីនេះក៏មាននៅក្នុងទំនៀមអ្នកស្រុកផងដែរ ដែលគេហៅឈ្មោះប្លែកៗគ្នាដូចជា «បូជាភ្លើង» ឬ «ពូនភ្នំស្រូវ ឬដុតភ្នំស្រូវ»។[៦] ដូច្នេះហើយទើបយើងឃើញមានទួលអង្គរខ្មៅនេះ មាននៅខេត្តស្ទឹងត្រែងនិងនៅបន្ទាយមានជ័យ។ ការដុតនេះទៀតសោត យើងអាចយល់បានថាជាប់ទាក់ទងនឹងកិច្ចបូជាថ្វាយទេពតាមរយៈព្រះអគ្គី។

---

[៣] លី ធាមតេង, ១៩៧៣: ៤០

[៤] វចនានុក្រមខ្មែរ ភាគ១, ១៩៦៧: ៤០៨

[៥] ចាប ពិន, ១៩៦៩: ១៤៥-១៤៨

[៦] ពេជ្រ សល់, ១៩៦៦: ៧២

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

កាលដើមឡើយស្រូវទាំងអស់ក្នុងកិច្ចនោះត្រូវដុតទាំងអស់ លុះក្រោយមកនៅពេលកាន់ពុទ្ធសាសនាថេរវាទគេយកស្រូវនោះលក់ ដើម្បីយកកម្រៃដាក់ជាប្រយោជន៍វត្តវិញ។[៧] កិច្ចនេះហើយដែលក្លាយមកជាពិធីពូនភ្នំស្រូវ ដោយធ្វើនៅតាមភូមិស្រុកក្រោយពេលប្រមូលផលរួច ដោយពុំដុតទៀតទេ ដ្បិតស្រូវនោះទុកប្រើប្រាស់ជាប្រយោជន៍របស់វត្តអារាមជាដើម។ «ពូនភ្នំស្រូវ» ឬ «ដុតភ្នំស្រូវ» នេះ ជាកិច្ចពិធីក្នុងវិស័យកសិកម្ម ដែលហាក់ដូចជាបង្ហាញពីការបូជាភោគផលថ្វាយទេពផង និងត្រៀមសម្រាប់រដូវកសិកម្មខាងមុខផង ដ្បិតឯកសារសម្ដេចឥសីភទ្ទធបតី ម៉ាំង បញ្ជាក់ថាស្រូវដែលលត់ទឹកក្នុងកិច្ចពិធីនោះរួច អាចារ្យវាល់ចែកចៅហ្វាយស្រុកទុកចែករាស្ត្រប្រជាធ្វើជាពូជសាប ឯស្ដេចមាយជិះដំរីឱបព្រលឹងស្រូវហៅទៅឃ្លាំងស្រូវ។

ដូចបានបង្ហាញខាងលើនេះ «ទួលអង្ករខ្មៅ» គឺជាទួលកើតឡើងដោយសារខ្មែរយើងពីជំនាន់មុនបានធ្វើពិធី «ដុតស្រូវ» ឬ «ដុតភ្នំស្រូវ» នេះឯង។ តាមរយៈសិលាចារឹក ទីលានដុតស្រូវនោះហៅថា «ក្រឡាដុតស្រូវ» (ក្រលាតុតិស្រូ)។ យើងពុំប្រាកដថាពិធីនេះមានចាប់តាំងពីពេលណាមកនោះឡើយ ប៉ុន្តែតាមរយៈសិលាចារឹក ពាក្យដុតស្រូវ ដែលចាស់ជាងគេ ឃើញមានក្នុងសិលាចារឹកប្រាសាទលាក់នាង នាពាក់កណ្ដាលស.វ.ទី១០។

---

[៧] សូមអាន ពេជ្រ សល់, ១៩៦៦: ៧២។

# បញ្ជីរូបភាព



ទួលអង្ករខ្មៅ ស្រុកថាឡាបរិវ៉ាត់ (ថតឆ្នាំ២០១៦)



ទួលអង្ករខ្មៅ ស្រុកថាឡាបរិវ៉ាត់ (ថតឆ្នាំ២០១៦)



អង្ករខ្មៅ ស្រុកថាឡាបរិវ៉ាត់ (ថតឆ្នាំ២០១៦)



អង្ករខ្មៅនៅស្រុកមង្គលបុរី (រូបថត៖ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្តបន្ទាយមានជ័យ)



សិលាចារឹកប្រាសាទលាក់នាង K.265 (រូបថត EFEO)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ឯកសារយោង

ចាប ពិន

១៩៦៩. ព្រះរាជពិធីទ្វាទសមាស ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

ពុទ្ធសាសនបណ្ឌិត្យ

១៩៦៧. វចនានុក្រមខ្មែរ ភាគ១, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

ពេជ្រ សល់

១៩៩៦. ពិធីប្រចាំដប់ពីរខែ, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

លី ធាមតេង

១៩៧៣. កំណត់ហេតុរបស់ជីវតាក្វាន់ អំពីប្រពៃណីអ្នកស្រុកចេនឡា, ភ្នំពេញ។

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION